អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គភាពគាំពារជនរងគ្រោះ**
**Victims Support Section**
**Section dáppui aux victimes**

# របាយការណ៍

# សិក្ខាសាលាបណ្តុះបណ្តាលស្តីពី "វេទយិតភាពយេនឌ័រ និងយុត្តិធម៌អន្តរកាល សម្រាប់មន្ត្រី អ.វ.ត.ក"




**ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១២ រាជធានីភ្នំពេញ ប្រទេសកម្ពុជា**

**ផ្តល់មូលនិធិដោយ**

**មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិដើម្បីបញ្ចប់អំពើហិង្សាប្រឆាំងនឹងស្ត្រី**

UNITED NATIONS TRUST FUND TO END VIOLENCE AGAINST WOMEN

**មាតិកា** **ទំព័រ**

ឈ្មោះកាត់ និងអក្សរកាត់..........................................................................៣

I. សាវតារ..........................................................................៣

១. កម្មវត្ថុ..........................................................................៤

២. គោលបំណង..........................................................................៤

II. សិក្ខាសាលា..........................................................................៤

១. ពិធីបើកសិក្ខាសាលា..........................................................................៤

២. វេទយិតភាពយេនឌ័រ និងយុត្តិធម៌អន្តរកាល..........................................៥

៣. វគ្គក្រុមតូចៗ..........................................................................៩

៤. ការវាយតម្លៃសិក្ខាសាលា..........................................................................១៥

III. ពិធីបិទសិក្ខាសាលា..........................................................................២០

បញ្ជីឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធ ១ ៖ របៀបវារៈ..........................................................................២១

## ឈ្មោះកាត់ និងអក្សរកាត់

- ASF ក្រុមមេធាវីគ្មានព្រំដែន
- CPL មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី
- ECCC អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- GIZ Die Deutsche Gesellschaft fur Internationale Zusammenarbeit
- OCP ការិយាល័យសហព្រះរាជអាជ្ញា
- OCIJ ការិយាល័យសហចៅក្រមស៊ើបអង្កេត
- TC អង្គជំនុំជម្រះសាលាដំបូង
- PAS ផ្នែកកិច្ចការសាធារណៈ
- PTC អង្គបុរេជំនុំជម្រះ
- SCJ ចៅក្រមតុលាការកំពូល
- WESU អង្គភាពគាំពារសាក្សី និងអ្នកជំនាញ
- ITU អង្គភាពបកប្រែភាសា
- VSS ផ្នែកគាំពារជនរងគ្រោះ

## I. សេចក្តីផ្តើម

នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១២ អង្គភាពគាំពារជនរងគ្រោះ (VSS) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយមានការសហការជាមួយនឹងអង្គការចិត្តសង្គម-អន្តរវប្បធម៌ (TPO) និងក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) បានរៀបចំសិក្ខាសាលាស្តីពី “វេទយិតភាពយេនឌ័រ និងយុត្តិធម៌អន្តរកាល” ដើម្បីបណ្តុះបណ្តាលមន្ត្រី អ.វ.ត.ក។ សិក្ខាសាលានេះត្រូវបានសម្របសម្រួលដោយ លោកស្រី Caitlin Reiger ដែលជាទីប្រឹក្សាជំនាញ និងបានរៀបចំឡើងនៅក្នុងបរិវេណ អ.វ.ត.ក (បន្ទប់ C210) ។ សិក្ខាសាលានេះមានសិក្ខាកាមមកពីការិយាល័យផ្សេងៗនៅ អ.វ.ត.ក ចូលរួមចំនួន ៤២ នាក់ (នារី ២៤ នាក់ និងបុរស ១៨ នាក់)។

### ១. កម្មវត្ថុ

វគ្គបណ្តុះបណ្តាលនេះបានផ្តោតសំខាន់លើការបង្កើនការយល់ដឹងដល់មន្ត្រី អំពីវិធីការពារ និងលើកកម្ពស់បញ្ហាយេនឌ័រ ឲ្យកាន់តែប្រសើរឡើង នៅក្នុងបរិបទនៃយន្តការយុត្តិធម៌អន្តរកាលតាមផ្លូវតុលាការដូច អ.វ.ត.ក ជាដើម។

### ២. គោលបំណង

សិក្ខាសាលានេះមានគោលបំណងជម្រុញដល់មន្ត្រី អ.វ.ត.ក ទាំងអស់ ឲ្យចំណាយពេលវេលាបំពេញការងារប្រចាំថ្ងៃរបស់ខ្លួន មកស្វែងយល់ឲ្យកាន់តែប្រសើរឡើងលើគោលការណ៍មូលដ្ឋាននៃយុត្តិធម៌អន្តរកាល (វិធីដែល អ.វ.ត.ក ចូលរួមចំណែកនៅក្នុងកិច្ចប្រឹងប្រែងរបស់កម្ពុជាក្នុងការដោះស្រាយរឿងរ៉ាវអតីតកាលរបស់ខ្លួន) ដើម្បីធានាឲ្យបានថា ផលប្រយោជន៍ជាក់លាក់ និងចំណាប់អារម្មណ៍អំពីយេនឌ័រត្រូវបានការពារ និងលើកកម្ពស់យ៉ាងត្រឹមត្រូវ។ វគ្គបណ្តុះបណ្តាលនេះក៏មានបំណងផ្តល់ឱកាសឲ្យមន្ត្រីច្បាប់អភិវឌ្ឍវិធីសាស្ត្រជាក់ស្តែង ដើម្បីច្របាច់បញ្ចូលបញ្ហាទាំងនេះជាមួយនឹងការងាររបស់ខ្លួនក្នុងដំណាក់កាលបច្ចុប្បន្ននៃដំណើរការរបស់ អ.វ.ត.ក។

## II. សិក្ខាសាលា

### ១. ពិធីបើកសិក្ខាសាលា

លោក អ៊ឹម សុភា មន្ត្រីសម្របសម្រួលកម្មវិធីផ្សព្វផ្សាយ បានថ្លែងសុន្ទរកថាបើកសិក្ខាសាលាក្នុងនាមលោក រោង ឈង ប្រធានអង្គភាពគាំពារជនរងគ្រោះ។ លោកបានគូសបញ្ជាក់អំពីសារៈសំខាន់នៃបញ្ហាទាំងនេះ និងកម្មវត្ថុនានាដែលត្រូវលើកឡើងនៅក្នុងសិក្ខាសាលានេះ ដែលផ្តោតលើប្រធានបទស្តីពី "វេទយិតភាពយេនឌ័រ និងយុត្តិធម៌អន្តរកាល"។ លោកបានថ្លែងឡើងថា ការយល់ដឹងអំពីបញ្ហាយុត្តិធម៌ពិតជាមានសារៈសំខាន់ណាស់ចំពោះនិរន្តភាពនៃកិច្ចដំណើរការនីតិវិធី។ លោកបានលើកឡើងបន្ថែមទៀតថា អង្គភាពគាំពារជនរងគ្រោះបានធ្វើការជាដៃគូរជាមួយនឹងអង្គការមួយចំនួន និង ជាពិសេស ជាមួយនឹងអង្គការសហប្រជាជាតិ ដើម្បីបង្កើតផែនការមួយ ដែលមានគោលដៅផ្តល់យុត្តិធម៌ជូនជនរងគ្រោះនៃសម័យខ្មែរក្រហម។ ទោះបីជាយ៉ាងនេះក្តី លោកក៏បានកត់សម្គាល់ផងដែរថា អ.វ.ត.ក ពុំមានលទ្ធភាពដោះស្រាយលើគ្រប់រូបភាពនៃតម្រូវការយុត្តិធម៌ឡើយ រីឯ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់សិក្ខាកាមឆ្លុះបញ្ចាំងនូវវិធានការបំពេញបន្ថែមចាំបាច់ផ្សេងទៀតផងដែរ។ អំពើហិង្សាផ្លូវភេទ និងយេនឌ័រ នៅក្នុងសម័យខ្មែរក្រហម គឺជាបញ្ហាទូទៅមួយដែលនៅទីបំផុតត្រូវបានចាប់ផ្តើមយកមកលាតត្រដាង ។ នៅក្នុងពេលជាមួយ

គ្នានេះដែរ អ.វ.ត.ក បានបោះជំហានការងាររបស់ខ្លួនទៅមុខបានយ៉ាងល្អប្រសើរ ហើយដោយហេតុថា នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ វាបង្ហាញឲ្យយើងយល់យ៉ាងច្បាស់ថា សិក្ខាសាលានេះនឹងពុំផ្តល់ចម្លើយ ឬ យុត្តិធម៌គ្រប់បែបយ៉ាងដែលជនរងគ្រោះជាច្រើនប្រាថ្នាចង់បានឡើយ។

លោក អ៊ឹម សុភា បានឧទ្ទេសនាមអ្នកសម្របសម្រួលសិក្ខាសាលា គឺ លោកស្រី Caitlin Reiger ដែលពីមុន លោកស្រី គឺជាអ្នកជំនាញយូរឆ្នាំហើយប្រចាំមជ្ឈមណ្ឌលអន្តរជាតិដើម្បីយុត្តិធម៌អន្តរកាល (ICTJ)។ លោកស្រី Caitlin Reiger គឺជាមេធាវីដែលមានសញ្ជាតិអូស្រ្តាលី ដែលបានបម្រើការងារលើវិស័យយុត្តិធម៌អន្តរកាល និងនីតិរដ្ឋសម័យក្រោយជម្លោះ ព្រមទាំងវិស័យសិទ្ធិមនុស្ស អស់រយៈពេលជាងមួយទសវត្សរ៍។ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ លោកស្រីបម្រើការងារជានាយិកាផ្នែកទំនាក់ទំនងគោលនយោបាយអន្តរជាតិនៅមជ្ឈមណ្ឌលអន្តរជាតិដើម្បីយុត្តិធម៌អន្តរកាល (ICTJ) ហើយចាប់ពីឆ្នាំ ២០០៥-២០១០ លោកស្រីគឺជានាយិការងផ្នែកកម្មវិធីអយ្យការនៅ ICTJ និងបានដឹកនាំការងាររបស់ ICTJ នៅក្នុងប្រទេសកម្ពុជា និងអតីតប្រទេសយូហ្គោស្លាវី។ លោកស្រីបានផ្តល់យោបល់ប្រឹក្សាផ្នែកបច្ចេកទេស និងការវិភាគគោលនយោបាយសម្រាប់គំនិតផ្តួចផ្តើមយុត្តិធម៌សម័យក្រោយជម្លោះ និងសាលាក្តីកូនកាត់នានានៅតាមបណ្តាប្រទេសផ្សេងៗ។ ចាប់ពីឆ្នា ២០០៣ ដល់ ឆ្នាំ ២០០៥ លោកស្រីបម្រើការងារជាទីប្រឹក្សាជាន់ខ្ពស់សម្រាប់ចៅក្រម នៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (SCSL) ហើយនៅក្នុងឆ្នាំ ២០០១ លោកស្រីគឺជាសហស្ថាបនិកនៃកម្មវិធីតាម ដានប្រព័ន្ធតុលាការនៅប្រទេសទីម័រខាងកើត ហើយក៏បានដើរតួនាទីជាមេធាវីការពារក្តីនៅចំពោះមុខក្រុមប្រឹក្សា ជំនុំជម្រះក្តីពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរផងដែរ។ លោកស្រីក៏ជាសាស្រ្តាចារ្យជំនួយនៅមជ្ឈមណ្ឌលកិច្ចការសកលលោកនៃសាកលវិទ្យាល័យញូវយ៉ក និងបានបោះពុម្ពផ្សាយសៀវភៅផ្សេងៗ រួមទាំង សៀវភៅស្តីពី ការចោទប្រកាន់ប្រមុខរដ្ឋ (Prosecuting Heads of State) (សាព័ត៌មានរបស់ សាកលវិទ្យាល័យ Cambridge ឆ្នាំ ២០០៩)។

**២. បទបង្ហាញស្តីពីវេទយិតភាពយេនឌ័រ និងយុត្តិធម៌អន្តរកាល ដោយលោកស្រី Caitlin Reiger**

ក្រោយពីបទឧទ្ទេសនាមដំបូងរបស់សិក្ខាកាមទាំងអស់គ្នារួចមក លោកស្រី Reiger បានចាប់ផ្តើមសិក្ខាសាលា ដោយបានពន្យល់សង្ខេបអំពីទស្សនាទាននៃយុត្តិធម៌អន្តរកាល ដោយលោកស្រីបានកត់សម្គាល់ថា វាយឺតបន្តិចហើយនៅក្នុងដំណើរការការងាររបស់ អ.វ.ត.ក ដែលនៅកំពុងបំពេញការងារនេះនៅឡើយ។ យុត្តិធម៌អន្តរកាលគឺជាដំណើរការ និងយន្តការលើវិស័យជាច្រើនពាក់ព័ន្ធនឹងបំណងរបស់សង្គមនៅក្នុងការដោះស្រាយកេរដំណែលនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងបានទទួលការជួយជ្រោមជ្រែងពីអង្គការសហប្រជាជាតិ និងពីក្របខណ្ឌគតិយុត្តអន្តរជាតិ ដែលដាក់កាតព្វកិច្ចលើរដ្ឋនានា និងទទួលស្គាល់

សិទ្ធិរបស់ជនរងគ្រោះក្នុងការស្វែងរកការពិត ក្នុងការទទួលបាននូវភាពយុត្តិធម៌ ក្នុងការទទួលបានសំណង និងក្នុងការទប់ស្កាត់កុំឲ្យកើតឡើងជាថ្មីទៀត។

បន្ទាប់មក លោកស្រី Reiger បានសាកសួរសិក្ខាកាមអំពីទស្សនាទាននៃវេទយិតភាពយេនឌ័រ ដោយពិនិត្យលើភាពខុសគ្នារវាងយេនឌ័រ (ការកំណត់បែបផែនដែលបានបង្កើតឡើងតាមបែបសង្គម និងការរំពឹងទុកដោយផ្អែកលើភេទ) និងភេទ (ចរិតលក្ខណៈជីវសាស្ត្រ/រូបសាស្ត្រ របស់ស្ត្រី និងបុរស)។ ផលប៉ះពាល់នៃតួនាទីយេនឌ័រ កើតចេញពីលក្ខណៈពិសេសរវាងវប្បធម៌ខុសគ្នា វិធីដែលបានសិក្សារៀនសូត្រ ហើយវាមានផលប៉ះពាល់លើការទទួលបានសិទ្ធិ និងធនធាននានារបស់ស្ត្រី និងបុរស។

ដើម្បីបង្ហាញចំណុចនេះ លោកស្រីបានយោងលើ**ច្បាប់ស្រី**ដែលជាទំនៀមទម្លាប់ដែលគេគោរពជាយូរមកហើយនៅក្នុងសង្គមកម្ពុជា។ សិក្ខាកាមបានបញ្ជាក់ថា **ច្បាប់ស្រី** គឺជា “ក្រមច្បាប់សម្រាប់ស្ត្រី” ដែលសរសេរឡើងជាកំណាព្យបុរាណមួយ សម្រាប់ឆ្លុះបញ្ចាំងវប្បធម៌របស់ប្រជាជនកម្ពុជា ពាក់ព័ន្ធនឹងអាកប្បកិរិយារបស់ស្ត្រី និងកុមារី។ ឧទាហរណ៍ផ្សេងទៀត រួមមាន ការហាមឃាត់ពីឪពុកម្តាយពុំអនុញ្ញាតឲ្យកូនស្រីទៅសាលារៀន ដោយសារមានការភ័យខ្លាចលួចលាក់មានសង្សារ។ សិក្ខាកាមមួយរូបបានកត់សម្គាល់ថា **ច្បាប់ស្រី** ត្រូវបានច្របាច់បញ្ចូលនៅក្នុងកម្មវិធីសិក្សាតាមសាលារដ្ឋ។ សិក្ខាកាមក៏ត្រូវបានសាកសួរឲ្យបង្ហាញអំពីទម្រង់នៃអំពើហិង្សាផ្អែកយេនឌ័រ ដែលកើតមាននៅក្នុងសង្គមកម្ពុជាសព្វថ្ងៃ ដែលរួមមាន ការជួញដូរស្ត្រី និងកុមារី អំពើហិង្សាលើស្ត្រីក្នុងរូបភាពងាយរងគ្រោះដូចជា ការជួលធ្វើការងារ (ការងារផ្លូវភេទ រោងចក្រកាត់ដេរ ការផ្សព្វផ្សាយស្រាបៀរ) ការវាយប្រហារដោយ អាស៊ីត និងអំពើហិង្សាក្នុងគ្រួសារ។ នេះជាបរិបទដែលស្ថិតក្នុងការងាររបស់ អ.វ.ត.ក ដែលកំពុងអនុវត្ត។

លោកស្រី Reiger បានគូសបញ្ជាក់ថា វេទយិតភាពយេនឌ័រ ពុំមែនត្រឹមតែផ្តោតលើការលើកកម្ពស់ការយល់ដឹងនោះទេ វាក៏រួមបញ្ចូលទាំងការប្រើប្រាស់វិធានការវិជ្ជមាននានាដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាននៃការទទួលយក និងការជឿជាក់លើយេនឌ័រ។

សិក្ខាកាមត្រូវបានស្នើសុំឲ្យបង្ហាញនូវទំនាក់ទំនងគ្នារវាងទស្សនាទានទាំងនេះ ជាមួយនឹងកម្មវត្ថុនៃការងាររបស់ អ.វ.ត.ក ដោយបង្ហាញជាឧទាហរណ៍នានាអំពីហិង្សាផ្អែកយេនឌ័រ នៅក្រោមរបបខ្មែរក្រហម។ តើការកំណត់បែបផែនយេនឌ័រប៉ះពាល់របៀបណាលើការយល់ដឹងរបស់យើងកម្រិតណាអំពីទម្រង់នៃព្យសនកម្មទាំងនេះ? បន្ទាប់មក ឧទាហរណ៍ទាំងនេះត្រូវបានប្រមូល និងដាក់បង្ហាញលើជញ្ជាំងក្នុងពេលដែលនៅសេសសល់សម្រាប់ថ្ងៃនោះ។ ក្នុងចំណោមអំណះអំណាងជាច្រើននោះ ឧទាហរណ៍មួយចំនួនត្រូវ

បានលើកឡើង រួមមាន ករណី ការបៀតបៀនផ្លូវភេទ ការរៀបការដោយបង្ខំ ការប្រព្រឹត្តចំពោះស្ត្រីមានផ្ទៃពោះ ឬ ដែលទើបសម្រាលកូនរួចជាដើម។

<table>
<tr><th colspan="2">ក្នុងសម័យខ្មែរក្រហម៖</th></tr>
<tr>
<td>- នារីៗត្រូវបានរំលោភដើម្បីជាថ្នូរនឹង អាហារ សុវត្ថិភាព ឱកាស<br>- ការរៀបការដោយបង្ខំដែលបុរស និងនារីបានទទួលរង<br>- ការរៀបការដោយបង្ខំ<br>- ការធ្វើឲ្យទៅជាទាសករផ្លូវភេទ<br>- ការបំបែកបំបាក់គ្រួសារ<br>- ការចាប់ពង្រត់កុមារ<br>- កាយវិកលកម្មផ្លូវភេទក្នុងពេលសួរចម្លើយ ឬ ក្នុងពេលឃុំខ្លួន<br>- ពុំបានពិចារណាស្ថានភាពជាក់លាក់ដែលប៉ះពាល់ដល់ស្ត្រី ដូចជា ពលកម្មដោយបង្ខំក្នុងពេលមានផ្ទៃពោះជិតគ្រប់ខែ ឬ ក្រោយពេលសម្រាលកូនភ្លាម<br>- កង្វះអនាម័យ អាចប៉ះពាល់នារីច្រើនជាងបុរស<br>- ក្រោមរបបខ្មែរក្រហម នារីកម្ពុជាទទួលរងគ្រោះដោយការរំលោភបំពានលើ៖<br>* ខ្វះការយកចិត្តទុកដាក់៖ នៅមុនពេលសម្រាលកូន និងពេលសម្រាលកូន<br>- នារីពុំទទួលបានសេវាសុខភាពមូលដ្ឋាន<br>- នារីចាំបាច់ត្រូវធ្វើការដូចបុរស</td>
<td>- អំពើហិង្សាផ្លូវភេទ និងយេនឌ័រ ក្រោមរបបខ្មែរក្រហម<br>* ការរំលោភផ្លូវភេទ* ការរៀបការដោយបង្ខំ៖គ្មានសិទ្ធិសម្រេចចិត្តរើសប្តីប្រពន្ធជាគូអនាគត<br><br>- ការរៀបការដោយមានការរៀបចំសម្រាប់ទាហានខ្មែរក្រហម ជាមួយនារីៗនៅក្នុងសហករណ៍ ដែលទាហានខ្មែរក្រហមទាំងនេះមានសិទ្ធិជ្រើសរើសនារី<br>ដែលខ្លួនចង់រៀបការជាមួយ រីឯនារីៗមានការលំបាកនឹងមានសិទ្ធិជ្រើសរើសដូចនេះណាស់។<br>- ប្រសិនបើប្តី/បុគ្គលិកត្រូវបានចាប់ខ្លួន នារី និងកុមារក៏ត្រូវចាប់ខ្លួនដូចគ្នា ទោះបីពុំបានប្រព្រឹត្តអ្វីខុសក៏ដោយ<br>- នារី ទំនងជាត្រូវបានបង្ខំឲ្យរៀបការ<br>- បង្ខំឲ្យធ្វើការងារប្រើកម្លាំងធ្ងន់ធ្ងរបាក់កម្លាំង<br>- នារីធ្វើការងារលើសពី ១០ ម៉ោងក្នុងមួយថ្ងៃ ដូចជា ការច្រូតកាត់ ជាដើម<br>- អំពើហិង្សាក្នុងគ្រួសារ</td>
</tr>
</table>

| | |
|---|---|
| ដោយមិនគិតអំពីយេនឌ័រ<br>- នារីត្រូវបានបង្ខំឲ្យធ្វើការងារដូចបុរស ក្រោយពេលទើបសម្រាលកូនរួច | - ការរំលោភផ្លូវភេទ<br>- ការរៀបការដោយបង្ខំ<br>- ការបង្ខំឲ្យអាក្រាតកាយ |

លោកស្រីបានស្នើសុំសិក្ខាកាមឲ្យឆ្លុះបញ្ចាំងថា តើឧក្រិដ្ឋកម្មខ្លះដែលប្រព្រឹត្តលើបុរស និងនារីត្រូវបានប្រើប្រាស់វិធីយេនឌ័រជាក់លាក់ខុសៗគ្នា ដូចជា នៅពេលមានការសម្លុតនារី ឲ្យរៀបការជាមួយនឹងទាហានពិការ ប្រសិនបើពួកគេបដិសេធពុំព្រមគោរពតាមការរៀបការដោយបង្ខំនេះ។ លោកស្រី Reiger ក៏បានលើកយកបទពិសោធន៍ស្តីពីយេនឌ័រក្នុងពេលជម្លោះនៅក្នុងប្រទេសផ្សេងៗ មកបង្ហាញផងដែរ។ ឧទាហរណ៍អំពីវិធីដែលនារីទទួលរងផលប៉ះពាល់ រួមមានការកាប់សម្លាប់ ការលំបាកលំបិនផ្នែកសេដ្ឋកិច្ចរយៈពេលយូរ ការបាត់បង់ទីលំនៅ អំពើហិង្សាពាក់ព័ន្ធនឹងការបន្តពូជ និងផ្លូវភេទ ការធ្វើឲ្យទៅជាទាសករផ្លូវភេទ ការជ្រើសរើសឲ្យធ្វើការងារដោយបង្ខំ និងភាពចុះខ្សោយផ្នែកសុខភាព។ បន្ទាប់មកលោកស្រីបានលើកឡើងអំពីនីតិវិធីដែលដំណើរការយុត្តិធម៌អន្តរកាល បានឆ្លើយតបទៅនឹងបទពិសោធន៍ទាំងនេះ។ ឧទាហរណ៍ សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានអនុវត្តតាមវិធានភស្តុតាងជាក់លាក់ សម្រាប់ធ្វើការសួរដេញដោលសាក្សីដែលមកផ្តល់សក្ខីកម្មស្តីពីអំពើហិង្សាផ្លូវភេទ។

នៅក្នុងករណីប្រទេសទីម័រខាងកើត គណៈកម្មការស្វែងរកការពិតបានបង្កើតកញ្ចប់សំណាងជាក់លាក់មួយ និងបង្កើតឱកាសឲ្យនារីៗរៀបរាប់ពីការឈឺចាប់របស់ខ្លួន។ នៅក្នុងប្រទេសប៉េរូ ក្រុមផ្សព្វផ្សាយត្រូវបានបង្កើតឡើង ដើម្បីជួបជាមួយនារីៗនៅតាមទីជនបទ ដើម្បីជួយនារីទាំងអស់នោះ។ គណៈកម្មការស្វែងរកការពិតបានបង្កើនការពិនិត្យមើលការរំលោភបំពានលើស្ត្រី ហើយក៏ពិនិត្យមើល ដើមចមនៃអំពើហិង្សាផងដែរ ដូចជា បទពិសោធន៍របស់គណៈកម្មការនៅក្នុងប្រទេសលីបេរីយ៉ា ទីម័រ សេរ៉ាឡេអូន ជាដើម។ នៅក្នុងករណីខ្លះ មានឧទាហរណ៍ជាវិជ្ជមានស្តីពីអនុសាសន៍ទាំងឡាយ ដែលនាំទៅរកការដោះស្រាយសំណង និងកំណែទម្រង់ស្ថាប័នដើម្បីការពារកុំឲ្យអំពើហិង្សាបែបនេះកើតមានជាថ្មីទៀត។

ក្នុងពេលពិភាក្សា សិក្ខាកាមបានបង្ហាញថា ព្រះរាជអាជ្ញាបានព្យាយាមបញ្ចូលបទចោទជាក់លាក់ពាក់ព័ន្ធនឹងយេនឌ័រ ទៅក្នុងសវនាការដំបូង ប៉ុន្តែថា វិសាលភាពនៃបទចោទទាំងនេះមានកម្រិត។ តើឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងយេនឌ័រអាចត្រូវបានលើកឡើងយ៉ាងដូចម្តេចនៅក្នុងស្ថានភាពបែបនេះ? អាចនឹងមានឱកាស ដូចជា នៅពេលដែលសាក្សីត្រូវបានអនុញ្ញាតឲ្យផ្តល់សក្ខីកម្មលើបទចោទទាំងអស់ ប្រសិនបើពួកគេចាស់ជរា និងពុំអាចរស់នៅរហូតដល់ពេលសវនាការនាពេលខាងមុខ។ បញ្ហាផ្សេងទៀត បានផ្តោត

លើបញ្ហាថា តើមានឧទាហរណ៍ផ្សេងទៀតស្តីពីអំពើហិង្សាផ្លូវភេទត្រូវបានចោទប្រកាន់ថាជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅមុនឆ្នាំ ១៩៧៥ ដែរឬទេ និងមានការលើកឡើងពីឧទាហរណ៍ស្តីពីប្រទេសបង់ក្លាដេសពាក់ព័ន្ធនឹងបញ្ហានេះផងដែរ។ លោកស្រី Reiger ក៏បានថ្លែងពីបទដ្ឋានទាំងឡាយ ដែលគ្រប់គ្រង អ.វ.ត.ក ទាំងផ្នែកជាតិ និងផ្នែកអន្តរជាតិ រួមមានកាតព្វកិច្ចនៅក្រោមសេចក្តីសម្រេចថ្មីៗរបស់ក្រុមប្រឹក្សាសន្តិសុខ (១៣២៥, ១៨៨៨, ១៨៨៩) ដើម្បីចាប់ចារីនៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រ យកមកទទួលទោសពីបទល្មើសរបស់ពួកគេ។

**៣. វគ្គក្រុមតូចៗ ៖ កំណត់បង្ហាញពីឱកាសនានាសម្រាប់លើកកម្ពស់វេទយិតភាពយេនឌ័រ និងយុត្តិធម៌អន្តរកាល នៅ អ.វ.ត.ក**

ក្រោយពេលឈប់សម្រាកអាហារថ្ងៃត្រង់ សិក្ខាកាមបានបំបែកគ្នាជាក្រុមតូចៗដើម្បីពិនិត្យមើលឱកាស និងយុទ្ធសាស្ត្រដែលអាចមាន ឲ្យបានលម្អិតជាងនេះ ដើម្បីលើកកម្ពស់វេទយិតភាពយេនឌ័រនៅក្នុងអំឡុងពេលសេសសល់ក្នុងដំណើរការតុលាការ។ ក្រុមនីមួយៗបានផ្តោតលើទិដ្ឋភាពផ្សេងៗនៃការងាររបស់តុលាការ៖

ក្រុមទី១ ៖ កិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន

ក្រុមទី២ ៖ សំណង និងវិធានការក្រៅផ្លូវតុលាការ

ក្រុមទី៣ ៖ ការចូលរួមជាមួយនឹងសហគមន៍

ក្រុមទី៤ ៖ វប្បធម៌នៃស្ថាប័ន អ.វ.ត.ក

បន្ទាប់មក របកគំហើញរបស់ក្រុមនីមួយៗ ត្រូវបានធ្វើបទបង្ហាញជូនសិក្ខាកាមផ្សេងទៀតដូចខាងក្រោម៖

| **ក្រុមទី១ ÷ កិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន** | |
|---|---|
| **សំនួរ** | **ចម្លើយ** |
| ១. តើមានឱកាសណាខ្លះដើម្បីបង្ហាញចំណុចសំខាន់ស្តីពីព្យសនកម្មជាក់លាក់ខាងយេនឌ័រ នៅក្នុងសំណុំរឿង ០០២/១? ការជម្លៀសដោយបង្ខំ? វចនាសម្ព័ន្ធផ្នែកទំនាក់ទំនង? | - ភស្តុតាងបង្ហាញអំពីរបៀប ដែលជនរងគ្រោះទទួលរងគ្រោះ ក្នុងនាមជា នារី<br>- អំពើហិង្សារំលោភផ្លូវភេទក្នុងពេលជម្លៀសដោយបង្ខំ<br>- ការបំបែកបំបាក់គ្រួសារ ៖ (ភាពងាយរងគ្រោះផ្នែករូបរាងកាយលើស្ត្រី និងគ្មាន |

| | |
|---|---|
| | ការការពារពីគ្រួសារ<br>- សំណងជាក់លាក់លើយេនឌ័រ |
| ២. តើអាចបង្គាប់ឲ្យមានការស៊ើបអង្កេតបន្ថែមទៀតដែរឬទេ? | - ការស៊ើបអង្កេតបន្ថែម<br>- វិធានអនុញ្ញាតឲ្យមាន ក៏ប៉ុន្តែ ពិបាកអនុវត្ត |
| ៣. តើបទចោទដែលនៅសល់ដោះស្រាយលើអំពើហិង្សាលើយេនឌ័រដោយរបៀបណា? | - ការរៀបការដោយបង្ខំ និងការរំលោភផ្លូវភេទ<br>- ការធ្វើពលកម្មដោយបង្ខំ<br>- ការរំលោភផ្លូវភេទដែលជាផ្នែកមួយនៃការធ្វើទារុណកម្ម ឬ មុនពេលសម្លាប់<br>- ការរំលោភផ្លូវភេទ និងការកាប់សម្លាប់ប្រពន្ធរបស់ទាហាន លន់ នល់ |
| ៤. តើមានវិធីផ្សេងទៀតដែលការដំណើរការជំនុំជម្រះអាចមានការគិតគូរលើបញ្ហាយេនឌ័របន្ថែមទៀតដែរឬទេ? | - សំណុំរឿង ០០៤ ៖ ការស៊ើបអង្កេតកំពុងបន្ត → ផ្តោតលើអំពើហិង្សាលើយេនឌ័រ |
| ៥. តើមានឱកាសអ្វីខ្លះនៅក្នុងបរិបទនៃសំណុំរឿង ០០៣/៤? | - ប្រភេទភស្តុតាងដែលបានស្តាប់ឮ (បទពិសោធន៍របស់នារី ដែលជាស្ថានទម្ងន់ទោស)<br>- ការស្តាប់សាក្សីជានារី និងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីបង្ហាញផលប៉ះពាល់ជាក់លាក់ |
| ៦. សូមរៀបរាប់ចំណុច ៣ យ៉ាង ដែលចាំបាច់ក្នុងការលើកកម្ពស់វេទយិតភាពយេនឌ័រនៅ អ.វ.ត.ក? | - ធ្វើឲ្យមានតុល្យភាពយេនឌ័រផ្នែកបុគ្គលិក ឧ. អ្នកស៊ើបអង្កេត និងអ្នកបកប្រែ<br>- ធ្វើឲ្យមានតុល្យភាពយេនឌ័រលើការជ្រើសរើសសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី (អ្នករស់រានមានជីវិត)<br>- សំណងសម្រាប់ជនរងគ្រោះ COB |

| ក្រុមទី២ ÷ សំណាង និងវិធានការក្រៅផ្លូវតុលាការ | |
|---|---|
| **សំណួរ** | **ចម្លើយ** |
| ១. ពិនិត្យមើលឲ្យបានលម្អិតជាងនេះលើការបំបែកការទាមទារសំណងសំណងដោយផ្អែកតាមយេនឌ័រ។ តើការបំបែកនេះអាចឲ្យអ្នកដឹងពីអ្វីខ្លះ? តើមានបញ្ហាចោទថ្មីៗអ្វីខ្លះកើតមានឡើង? | - នារីកាន់តែច្រើនជាជនរងគ្រោះ/ឈឺចាប់<br>- នារីកាន់តែច្រើនចាប់អារម្មណ៍លើដំណើរការតុលាការ<br>- នារីកាន់តែច្រើនជាអ្នកនៅរស់រានមានជីវិត<br>- បញ្ហាចោទថ្មីៗ ៖<br>- តើដោះស្រាយលើតម្រូវការរបស់ជនរងគ្រោះជានារីដោយរបៀបណា?<br>- តើមានវិធីសាស្ត្របែបណាដើម្បីឆ្លើយតបទៅនឹងបញ្ហាយេនឌ័រពាក់ព័ន្ធនឹងរបបខ្មែរក្រហម? |
| ២. តើយេនឌ័រអាចពាក់ព័ន្ធកម្រិតណា នៅក្នុង ៖<br>• ការបង្កើតសំណើរួម (ដោយដើមបណ្តឹងរដ្ឋប្បវេណី/សហមេធាវីនាំមុខ)<br>• ការឆ្លើយតបទៅនឹងសំណើ (ដោយដើមបណ្តឹងរដ្ឋប្បវេណី)<br>• ការបង្កើតការបង្គាប់ឲ្យសងសំណង (ដោយអង្គជំនុំជម្រះសាលាដំបូង) | យេនឌ័រពាក់ព័ន្ធនឹង ៖<br>- ការបង្កើតសំណើរួម ៖<br>- ការរៀបចំគម្រោងសំណងត្រូវពិនិត្យមើលបញ្ហាយេនឌ័រ<br>- ការអនុវត្ត/សិទ្ធិវ័ន្តត្រូវដោះស្រាយ/ឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ<br>- ការចូលរួម - ការចូលរួមចំណែក - ផលប្រយោជន៍ របស់នារី |
| ៣. តើវិធានការក្រៅផ្លូវតុលាការពាក់ព័ន្ធនឹងវេទយិតភាពយេនឌ័រ មានលក្ខណៈយ៉ាងដូចម្តេច? | - កំណត់គម្រោងវិធានការក្រៅផ្លូវតុលាការជាក់លាក់ដែលអាចឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ<br>- ការចូលរួម - ការចូលរួមចំណែក - ផលប្រយោជន៍ របស់នារី |
| ៤. សូមរៀបរាប់ចំណុច ៣ យ៉ាង ដែលចាំបាច់ក្នុង | - សំឡេងរបស់នារីនៅក្នុងបន្ទប់តុលាការ |

| | |
|---|---|
| ការលើកកម្ពស់វេទយិតភាពយេនឌ័រនៅ អ.វ.ត.ក? | (ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី)<br>- គុណ្យភាពយេនឌ័រ គួរត្រូវបានដោះស្រាយនៅក្នុងគោលនយោបាយគ្រប់គ្រងធនធានមនុស្ស<br>- រាល់សំណើ/ការធ្វើសេចក្តីសម្រេចទាំងអស់គួរផ្តោតលើអាទិភាពយេនឌ័រ |
| **ក្រុមទី៣ ÷ ការចូលរួមជាមួយនឹងសហគមន៍** | |
| **សំណួរ** | **ចម្លើយ** |
| ១. តើ អ.វ.ត.ក គួរដោះស្រាយជូនបុគ្គលណា (ក្រៅពីបុគ្គលិកផ្ទាល់របស់ខ្លួន)? សូមរៀបរាប់អំពីអ្នកជាប់ពាក់ព័ន្ធនានាផ្សេងទៀត និងតើយេនឌ័រអាចពាក់ព័ន្ធបែបណា។ | - ជនរងគ្រោះ<br>- ដើមបណ្តឹងរដ្ឋប្បវេណី<br>- រដ្ឋាភិបាល<br>- សង្គមស៊ីវិល<br>- អ្នកជំនាញ/អ្នកស្រាវជ្រាវ<br>- សារព័ត៌មាន<br>- ម្ចាស់ជំនួយ<br>- សាធារណជន<br>- គណៈមេធាវី<br>- អ.ស.ប ក្រៅពី អ.វ.ត.ក<br>- សាកលវិទ្យាល័យ/សាលារៀន<br>- មេដឹកនាំសាសនា |
| ២. សូមស្នើ យ៉ាងហោចណាស់ វិធីចំនួន ៣ ដែលកម្មវិធីផ្សព្វផ្សាយរបស់ អ.វ.ត.ក អាចផ្តោតលើវេទយិតភាពយេនឌ័រកាន់តែខ្លាំង។ | - ដើមបណ្តឹងរដ្ឋប្បវេណី/ជនរងគ្រោះ ៖ ការសម្ងាត់រារាំងការផ្សព្វផ្សាយ រួមមានព័ត៌មានស្តីពីអង្គហេតុដែលរកឃើញដោយអ្នកនាំសារផ្នែកផ្សព្វផ្សាយ<br>- ការពង្រឹងអំណាចសម្រាប់នារី តាមរយៈ ការប្រជុំ ការបណ្តុះបណ្តាល ការបង្កើកហ្វឹន |

| | |
|---|---|
| | វេទិកាអំពីសិទ្ធិរបស់ពួកគេក្នុងនាមដើមបណ្ដឹងរដ្ឋប្បវេណី<br>- ក្រុមនារីសម្រាប់ពិភាក្សាគ្នា<br>- ការសហការជាមួយនឹងគណៈកម្មាធិការនារីនៅតាមក្រុមប្រឹក្សាឃុំ/ខេត្ត<br>- ការបណ្ដុះបណ្ដាលសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី |
| ៣. តើ អ.វ.ត.ក អាចការពារប្រឆាំងនឹងការបង្កើនការកំណត់បែបផែនយេនឌ័រ តាមវិធីណា? | - សុំឱ្យមានគំនិតផ្ដួចផ្ដើមច្រើនជាងមុន/វិជ្ជាជីវៈទាំងឡាយមិនត្រូវអនុវត្តតាមការកំណត់បែបផែនយេនឌ័រ និងជាគំរូ ឧ. សន្តិសុខនារី អ្នកបើកបរនារី អ្នកបកប្រែនារី មេធាវីនារី<br>- បុគ្គលិកនារីចូលរួមនៅក្នុងតុលាការជាឧទាហរណ៍ (ព្រះរាជអាជ្ញា មេធាវីការពារក្ដីភាគច្រើនជាបុរស និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីមាននារីច្រើន |
| ៤. តើ អ.វ.ត.ក អាចជម្រុញឱ្យមានដំណើរការយុត្តិធម៌អន្តរកាលបន្ថែម រួមទាំង ដំណើរការដែលដោះស្រាយជាមួយនឹងអំពើហិង្សាយេនឌ័រ តាមវិធីណា? | - ការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់អង្គការក្រៅរដ្ឋាភិបាល<br>- ការបញ្ជូនរបាយការណ៍ទៅគម្រោងបែបនេះ |
| ៥. សូមរៀបរាប់ចំណុច ៣ យ៉ាង ដែលចាំបាច់ដើម្បីលើកកម្ពស់វេទយិតភាពយេនឌ័រ នៅ អ.វ.ត.ក? | - ចំណុចប្រសព្វផ្នែកយេនឌ័រដែលឯករាជ្យដែលបានគាំទ្រដោយភាគីជាតិ និងអន្តរជាតិ<br>- ការបញ្ចូលព័ត៌មានទៅក្នុងឯកសារបោះពុម្ពផ្សាយរបស់តុលាការ<br>- លើកកម្ពស់គោលនយោបាយធនធានមនុស្សដើម្បីជាគំរូ |

| ក្រុមទី៤ ÷ វប្បធម៌ស្ថាប័ន អ.វ.ត.ក | |
|---|---|
| **សំណួរ** | **ចម្លើយ** |
| ១. សូមរៀបរាប់ឧទាហរណ៍ខ្លះៗ ស្តីអំពីថាតើបរិយាកាសការងារនៅ អ.វ.ត.ក ប៉ះពាល់បុរស និងនារី ខុសគ្នាយ៉ាងដូចម្តេច? | - បុរសដែលកំពុងធ្វើការ នៅ អ.វ.ត.ក / នៅ UNAKRT មានច្រើនជាង<br>ឧ. ជាទូទៅ (ជាពិសេស តួនាទីដឹកនាំ) ការិយាល័យតុលាការ និងអង្គជំនុំជម្រះ ១៧% ជានារី និង ៨៣% ជាបុរស |
| ២. តើអ្នកមានធ្លាប់ឆ្លងកាត់បទពិសោធន៍លើកកម្ពស់យេនឌ័រនៅក្នុងបរិយាកាសការងារផ្សេងៗ ល្អជាងនេះ ឬ អាក្រក់ជាងនេះដែរឬទេ? | - ដោយសារបញ្ហាភាសា ពិបាកនឹងប្រាប់ថាតើជាកម្លាំងជម្រុញអ្វី ពីមួយថ្ងៃទៅមួយថ្ងៃ<br>- ពុំមានការទាក់ទងរវាងបុគ្គលិកជាតិ និងអន្តរជាតិ<br>- ការពិចារណាលើស្ថាប័ន លើការជ្រើសរើស និងលើមាតុភាព -ពុំល្អសម្រាប់ពួកបស្ចិមប្រទេស/ល្អសម្រាប់ជនជាតិកម្ពុជា |
| ៣. នៅពេលអ្នកពិចារណាលើពេលវេលារបស់អ្នកក្នុងនាមជាបុគ្គលិក អ.វ.ត.ក/UNAKRT តើអ្នកនឹងប្រាប់អ្វីខ្លះដល់ចៅៗរបស់អ្នកអំពីបទពិសោធន៍? | - សេចក្តីសង្ឃឹមរបស់ អ.វ.ត.ក មានច្រើន/គួរឲ្យចាប់អារម្មណ៍<br>- ភាពក្មៀវក្លា (UNAKRT)<br>- ស្វែងយល់ពីវា<br>- ដឹងច្រើនអំពីខ្មែរក្រហម ៖ យល់ថា វាពិតជាកើតមាន ហើយនឹងចែករំលាយប្រវត្តិសាស្ត្រនេះទៅកាន់កូនៗ<br>- របៀបសម្របតាមបរិយាកាសពហុវប្បធម៌ នៅ អ.វ.ត.ក<br>- កិច្ចដំណើរការនីតិវិធីមានលក្ខណៈបើកចំហជាង/មានលក្ខណៈតទល់ជាងកិច្ច |

| | |
|---|---|
| | ដំណើរការនៅក្នុងស្រុក (ជាតិ)<br>- រៀនជៀសវាងភាពហួសហេតុនិយម → អំពីប្រវត្តិសាស្ត្រកម្ពុជា |
| ៤. សូមរៀបរាប់ចំណុច បី យ៉ាង ដែលចាំបាច់លើកកម្ពស់វេទយិតភាពយេនឌ័រ នៅ អ.វ.ត.ក? | - បើកចំហរឲ្យមានការជជែកគ្នា<br>- ការបង្កើនបុគ្គលិកនារី<br>- បណ្តុះបណ្តាលនារីនៅទីនេះ<br>- ប្រព័ន្ធគាំទ្រ<br>- ការបណ្តុះបណ្តាលនារី → ឱកាសអប់រំ |

**៤. ការវាយតម្លៃសិក្ខាសាលា**

ក្រោយពីបញ្ចប់សិក្ខាសាលា សិក្ខាកាមត្រូវបានស្នើសុំឲ្យបំពេញបែបបទវាយតម្លៃដើម្បីស្វែងយល់អំពីរបៀបដែលសិក្ខាកាមបានបង្កើនចំណេះដឹងរបស់ខ្លួនលើបញ្ហាវេទយិតភាពយេនឌ័រ និងយុត្តិធម៌អន្តរកាល។

| ស្ថាប័ន | សំណួរទី១ តើអ្នកយល់ថាសិក្ខាសាលានេះមានប្រយោជន៍ដែរឬទេ? | សំណួរទី២ តើអ្នកបានសិក្សាអ្វីថ្មីដែរឬទេ? | សំណួរទី៣ តើគួរកែលម្អសិក្ខា-សាលានេះតាមវិធីណា? | សំណួរទី៤ សូមរៀបរាប់សំណើសុំការបណ្តុះបណ្តាលបន្ថែមលើវិស័យនេះ? | សំណួរទី៥ មតិយោបល់ផ្សេងៗ |
|---|---|---|---|---|---|
| LCL | មាន វាជួយឲ្យយល់ដឹងពីអំពើហិង្សាយេនឌ័រ និងជាពិសេស វិធីបញ្ចូលវាជាមួយនឹងបរិបទរបស់ | មាន យើងអាចនិយាយដូច្នេះដោយសារវាបានឲ្យយើងយកចិត្តទុកដាក់យ៉ាងជ្រាលជ្រៅ | ត្រូវការពេលបន្ថែម និងព័ត៌មានលម្អិតស្តីពីខ្លឹមសារនៃអំពើហិង្សាលើយេនឌ័រនៅក្នុង | -ព័ត៌មានលម្អិតបន្ថែមអំពីយុត្តិធម៌អន្តរកាល<br>-ព័ត៌មានលម្អិតបន្ថែមអំពើ | សំណើសុំសិក្ខាសាលាបន្ថែម និងការពិភាក្សាលើបញ្ហាអំពើហិង្សាយេនឌ័រ |

| | | | | | |
|---|---|---|---|---|---|
| | អ.វ.ត.ក (កិច្ច ដំណើរការនីតិវិធី សំណងសម្រាប់ ជនរងគ្រោះ) | លើទស្សនាទាន អំពើហិង្សាលើ យេនឌ័រ | បរិបទខ្មែរ ក្រហម | ហិង្សាយេនឌ័រ -ចំណុចជាក់ លាក់ជាងមុន និងចំណុច លម្អិតជាងមុន ក្នុងវិធីបញ្ចូល អំពើហិង្សា យេនឌ័រនៅក្នុង អាណត្តិរបស់ អ.វ.ត.ក | និង អ.វ.ត.ក និងវិធីបញ្ចូល វានៅក្នុង ប្រព័ន្ធ យុត្តិធម៌ក្នុង ស្រុក |
| OCP | មាន ការពិភាក្សា ជាមួយនឹង សមាជិកមកពី ស្ថាប័នផ្សេង ទាក់ទិននឹងបញ្ហា នេះ គឺពិតជាជាប់ ពាក់ព័ន្ធគ្នា | មាន ការចែក រំលែកការគិត ពិចារណា ជាមួយនឹង ជនជាតិកម្ពុជា ជាពិសេស ដោយមានការ វាយតម្លៃ ស្មោះត្រង់ | មនុស្សកាន់តែ ច្រើនមាន ការពាក់ព័ន្ធ | ញឹកញាប់ជាង មុន | គ្មាន |
| | មាន វាអាចឲ្យ គ្រប់គ្នាចាប់ អារម្មណ៍លើ យេនឌ័រ និង យុត្តិធម៌អន្តរកាល នៅ អ.វ.ត.ក និង កសាងសន្ទុះលើ | មាន ខ្ញុំបាន ដឹងច្រើនលើ អំពើហិង្សា យេនឌ័រ ក្រោមរបបខ្មែរ ក្រហម នៅក្រោម | -បង្កើនចំណេះ ដឹងច្រើនជាងមុន លើយុត្តិធម៌ អន្តរកាល អំពើ ហិង្សាយេនឌ័រ ផ្ទុះបញ្ចាំងក្នុង សង្គមផ្សេងៗ | -ផ្តល់ឯកសារ ពាក់ព័ន្ធដល់ សិក្ខាកាមមុន ពេលចាប់ផ្តើម ការបណ្តុះ បណ្តាល -បកប្រែទៅជា | -មានចំនួន សិក្ខាកាម ជាបុរសតិច -សំណួរ សម្រាប់ក្រុម បុរសៗ ពិភាក្សាពុំបាន |

| | | | | | |
|---|---|---|---|---|---|
| | ទស្សនាទាននេះ | ប្រទេសផ្សេងៗ និង ការប៉ះទង្គិចរវាងវប្បធម៌ ទំនៀមទំលាប់ និង យេនឌ័រ | -ផ្តុះបញ្ចាំង គោលនយោ-បាយខ្លះដើម្បី កាត់បន្ថយ ការរើសអើង យេនឌ័រ និងបង្កើនកម្រិត សមភាព រវាងរវាងនារី និងបុរស -ពេញចិត្តនឹង ទទួលការបណ្តុះ បណ្តាលបន្ថែម ដើម្បីទទួលបាន ព័ត៌មានបន្ថែម | ភាសាខ្មែរ សម្រាប់ ឯកសារ សំខាន់ៗ -បង្កើនចំនួន សិក្ខាកាម ជាបុរស | ឆ្លើយតបត្រឹម ត្រូវ ឬពាក់ព័ន្ធ នឹងប្រធានបទ ហើយវាយឺត ពេលក្នុងការ សួរសំណួរក្នុង កិច្ចដំណើរការ នីតិវិធីបច្ចុប្បន្ន -បន្ថយចំនួន សិក្ខាកាម នៅពេល រសៀល |
| | ខ្ញុំយល់ថាវាគួរ ឲ្យចាប់អារម្មណ៍ នៅពេលស្តាប់ឮ ការពិភាក្សាលើ បញ្ហាប្រឈមផ្លូវ ច្បាប់នៅក្នុងបទ បង្ហាញ ក៏ដូចជា លើបញ្ហាបុគ្គលិក ជាតិផងដែរ | មានច្រើនអំពី វិធីសាស្ត្រ វប្បធម៌ និងគតិយុត្តិ សម្រាប់ SGSC | ខ្ញុំគិតថាមាន | គ្មាន | គ្មាន |
| | ខ្ញុំពិតជារីករាយ ដែលបានចូលរួម | នៅពេលជ្រើស រើសក្រុមតូច | អាចធ្វើតាមរយៈ របៀបវារៈ | ការបណ្តុះ បណ្តាល | |

| | | | | | |
|---|---|---|---|---|---|
| | សូមអរគុណអ្នកសម្របសម្រួល និងអ្នករៀបចំ | ដែលផ្តោតការយកចិត្តទុកដាក់លើខ្លឹមសារ ដែលខ្ញុំគិតថាមានសារៈសំខាន់ ប៉ុន្តែ វានៅក្រៅការទទួលខុសត្រូវរបស់ខ្ញុំ។ ខ្ញុំបានរៀនសូត្រច្រើនពីចក្ខុវិស័យលើបញ្ហាប្រឈមនានា។ | "បញ្ហាំងជាមុន" ដែលផ្តោតលើប្រធានបទដែលមានច្រើនផ្នែក ដើម្បីលើកឡើងបន្ថែមទៀត អំពីការកាន់តែចុះថយនៃការយកចិត្តទុកដាក់ | ចាំបាច់ត្រូវផ្លាស់ប្តូរក្រុមជនរងគ្រោះ ឬសង្គមស៊ីវិល ដែលអាចមានស្រាប់ | |
| CPLs | ខ្ញុំចាប់អារម្មណ៍ច្រើនពីសិក្ខាសាលានេះ ក្នុងនាមជាសិក្ខាកាមនារីនៅក្នុងយុត្តិធម៌អន្តរកាលនៅ អ.វ.ត.ក និងផលប្រយោជន៍ និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាស្ត្រីនៅក្នុងតុលាការ | ខ្ញុំទទួលបានចំណេះដឹងថ្មីលើ -ផលប៉ះពាល់នៃការរំលោភបំពានយេនឌ័រ ជាពិសេសការរំលោភបំពានលើស្ត្រី និងកុមារ ដែលកើតមាននៅក្នុងសម័យខ្មែរក្រហម -ចំណេះដឹងនៃការកាត់បន្ថយ | -យល់ច្បាស់លើគ្រប់ចំណុចស្តីពីយេនឌ័រ -នារីត្រូវចូលរួមដើម្បីលើកកម្ពស់សមត្ថភាពរបស់ខ្លួន ជាពិសេសជនរងគ្រោះជាស្ត្រីត្រូវក្លាហានរាយការណ៍ និងនិយាយការពិតនូវហេតុ | -សូមផ្តល់ឯកសារមុនពេលចាប់ផ្តើមសិក្ខាសាលា និងបកប្រែជាភាសាខ្មែរ ដើម្បីសម្រួលដល់សិក្ខាកាម -ចូរឲ្យមានសិក្ខាកាមបុរសបន្ថែមទៀត ដើម្បីឲ្យយល់អំពីអត្ថន័យនៃ | -នៅក្នុងក្រុមពិភាក្សានីមួយៗគួរមានអ្នកបកប្រែ -រៀបចំក្រុមនីមួយៗឲ្យមានគុណភាពតាមចំនួនសិក្ខាកាម -ក្រោយពេលបញ្ចប់បទបង្ហាញរបស់ក្រុម |

| | | | | | |
|---|---|---|---|---|---|
| | | អំពើហិង្សាលើយេនឌ័រ<br>-ចំណេះដឹងថ្មីអំពីវប្បធម៌ប្រពៃណី និងស្ត្រី | ការណ៍ដែលខ្លួនជួបប្រទះ<br>-សំណងត្រូវផ្តល់ជូនជនរងគ្រោះ<br>-ជនរងគ្រោះត្រូវទទួលបានយុត្តិធម៌ពិតប្រាកដ | សិក្ខាសាលាមិនដូច្នេះទេ សិក្ខាសាលានេះពុំមានលទ្ធផលល្អដែលយើងចង់បានឡើយ | នីមួយៗ យើងគួរមានពេលផ្តល់យោបល់<br>-បង្កើនចំនួនសិក្ខាកាមដើម្បីបង្ហាញការគោរពដល់នារីក្នុងពេលសិក្ខាសាលារហូតដល់ចប់ |

## III. ពិធីបិទសិក្ខាសាលា

លោកស្រី Reiger បានបិទសិក្ខាសាលា និងថ្លែងអំណរគុណដល់មន្ត្រីទាំងអស់ដែលបានចូលរួម។ ការពិភាក្សាមានលក្ខណៈផុសផុលច្រើន រីឯបញ្ហាប្រឈមនានាគឺទុកឲ្យសិក្ខាកាមអនុវត្តយុទ្ធសាស្ត្រដែលខ្លួនបានកំណត់ នៅពេលត្រឡប់ទៅបំពេញការងារវិញ។

## បញ្ជីឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធ ១ ៖ របៀបវារៈ

# របៀបវារៈ

# សិក្ខាសាលាស្តីពីវេទយិតភាពយេនឌ័រ និងយុត្តិធម៌អន្តរកាលសម្រាប់មន្ត្រី អ.វ.ត.ក

## ទីតាំង ៖ បន្ទប់ C210 ថ្ងៃ សុក្រ ទី ២២ ខែ មិថុនា ឆ្នាំ ២០១២

## វេលាម៉ោង ៩:០០ - ៣:៣០ រសៀល

| ម៉ោង | សកម្មភាព |
|---|---|
| ៨:៣០ - ៩:០០ ព្រឹក | ចុះឈ្មោះ |
| ៩:០០ - ៩:១០ ព្រឹក | សុន្ទរកថាថ្លែងស្វាគមន៍ដោយលោក អ៊ឹម សុភា មន្ត្រីសម្របសម្របកម្មវិធីផ្សព្វផ្សាយនៃអង្គភាពគាំពារជនរងគ្រោះ / អ.វ.ត.ក |
| ៩:១០ - ៩:៣០ ព្រឹក | **សេចក្តីផ្តើម និងការស្វែងយល់លើវាក្យស័ព្ទ** *តើអ្វីទៅជាយុត្តិធម៌អន្តរកាល? តើអ្វីទៅជាវេទយិតភាពយេនឌ័រ? ហេតុអ្វីវាពាក់ព័ន្ធនឹងការងារ អ.វ.ត.ក?* |
| ៩:៣០ - ១០:០០ ព្រឹក | **តើអ្នកដឹងអ្វីខ្លះអំពីអំពើហិង្សាលើយេនឌ័រ និងផ្លូវភេទនៅក្នុងប្រទេសកម្ពុជា? ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? បច្ចុប្បន្ន?** *វគ្គនេះនឹងបង្ហាញរបកគំហើញពីការស្រាវជ្រាវថ្មីៗដែលលើកឡើងពីអំពើហិង្សាយេនឌ័រ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ មានលក្ខណៈទូទៅជាងការគិត។ តើអំពើហិង្សាយេនឌ័រគឺផ្តែក តែលើអំពើហិង្សាផ្លូវភេទ/ការរំលោភផ្លូវភេទ ទេឬ? ដើម្បីផ្តល់បរិបទខ្លះចំពោះភាពពាក់ព័ន្ធនៅក្នុងការងាររបស់ អ.វ.ត.ក បច្ចុប្បន្ន វគ្គនេះនឹងពិនិត្យមើលថាតើបញ្ហាស្រដៀងៗគ្នា ដែលកំពុងដោះស្រាយនាពេលបច្ចុប្បន្នបានចាត់ការដោយរបៀបណានៅក្រោមប្រព័ន្ធយុត្តធម៌កម្ពុជាសព្វថ្ងៃ។* |
| ១០:០០ - ១០:៤៥ ព្រឹក | **បទពិសោធន៍យេនឌ័រ និងយុត្តិធម៌អន្តរកាល ពីបរិបទស្រដៀងគ្នា។** *វគ្គនេះនឹងផ្តល់ទស្សនាទានទូទៅអំពីបទពិសោធន៍ ដែលទាញចេញពីបរិបទក្រោយជម្លោះ រួមមានវិធីដែលវប្បធម៌ហិង្សា និងនិទណ្ឌភាពបានប៉ះពាល់ដល់នារី និងបុរស តាមបែបខុសៗគ្នា។ តើវាមានផលប៉ះពាល់យ៉ាងដូចម្តេចលើបទពិសោធន៍នៃព្យសនកម្មដែលពួកគេបានទទួលរង និងលទ្ធភាពរបស់ពួកគេ* |

| | |
|---|---|
| | *ក្នុងការទទួលបានសំណងដោយប្រសិទ្ធភាព។* |
| ១០:៤៥ - ១១:០០ ព្រឹក | *សម្រាកពិសាកាហ្វេ* |
| ១១:០០ - ១២:០០ ថ្ងៃត្រង់ | **តើប្រធានបទនេះត្រូវគ្នានឹងអាណត្តិការងាររបស់ អ.វ.ត.ក ដោយរបៀបណា?**<br>*វគ្គនេះនឹងពិនិត្យមើលវិធីដែលបញ្ហាយុត្តិធម៌អន្តរកាល និងវេយិតភាពយេនឌ័រមានការជាប់ពាក់ព័ន្ធគ្នាដោយផ្ទាល់នឹងអាណត្តិការងាររបស់ អ.វ.ត.ក ក្នុងការចោទប្រកាន់មេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងសម័យកាលខ្មែរក្រហម។ តើមានបទដ្ឋានពាក់ព័ន្ធនៅក្នុងច្បាប់កម្ពុជា និងអន្តរជាតិដែរឬទេ? តើ អ.វ.ត.ក ធ្វើការងារនេះតាមវិធីណា មកទល់ពេលនេះ? តើនឹងមានផលប៉ះពាល់រយៈពេលយូរអ្វីខ្លះពីតុលាការសម្រាប់ជនរងគ្រោះនៃអំពើហិង្សាយេនឌ័រ?* |
| ១២:០០ - ១:៣០ រសៀល | *អាហារថ្ងៃត្រង់* |
| ១:៣០ - ២:៣០ រសៀល | **វគ្គបំបែកក្រុមតូចៗ ៖ កំណត់បង្ហាញពីឱកាសសម្រាប់ធ្វើឲ្យវេទយិតភាពយេនឌ័រ/យុត្តិធម៌អន្តរកាល ឲ្យកាន់តែមានភាពប្រសើរឡើងនៅ អ.វ.ត.ក។**<br>*វគ្គនេះនឹងបំបែកសិក្ខាកាមជាក្រុមតូចៗ ដើម្បីពិចារណារកមើលឲ្យបានលម្អិតអំពីឱកាស និងយុទ្ធសាស្ត្រដែលអាចមានសម្រាប់ដំណើរការតុលាការដែលនៅសេសសល់។ បញ្ហាដែលយកមកដោះស្រាយ អាចរួមមានកិច្ចដំណើរការតុលាការបច្ចុប្បន្ន សំណង និងវិធានការក្រៅផ្លូវតុលាការទំនាក់ទំនងខាងក្រៅ និងបរិយាកាសស្ថាប័នផ្ទាល់របស់ អ.វ.ត.ក។* |
| ២:៣០ - ២:៤៥ រសៀល | *សម្រាកពិសាកាហ្វេ* |
| ២:៤៥ - ៣:៣០ រសៀល | *ធ្វើរបាយការណ៍បូកសរុប* |
| ៣:៣០ រសៀល | *សុន្ទរកថាបិទសិក្ខាសាលា ដោយមន្ត្រីអង្គភាពគាំពារជនរងគ្រោះ / អ.វ.ត.ក* |